**គម្រោងបង្ហាញបច្ចេកវិទ្យាបង្កើនផលិតភាព**
**ជុំវិញតំបន់ទន្លេសាប** ( TSTD TA 7305-CAM )

# បច្ចេកទេសដាំដំណាំត្រសក់ផ្អែម




## ក. សេចក្តីផ្តើម

ខិត្តប័ណ្ណ បច្ចេកទេសដាំដំណាំត្រសក់ផ្អែម នេះ ត្រូវបានរៀបចំឡើង សម្រាប់កសិករ ដោយផ្អែកលើបទពិសោធន៍ធ្វើបង្ហាញបច្ចេកទេស ដាំដំណាំនេះ ក្នុងរដូវប្រាំង ដើមឆ្នាំ ២០១២ នៅ ខេត្តកំពង់ចាម និង កំពង់ធំ។ ខ្លឹមសារលំអិត រៀបរាប់ក្នុងខិត្តប័ណ្ណនេះ មានក្នុង *សៀវភៅណែនាំបច្ចេកទេសកសិករ ស្តីពីដំណាំត្រសក់ផ្អែម* ដែល អាចរកបាន តាមមន្ទីរកសិកម្មខេត្តគោលដៅ និងមណ្ឌលព័ត៌មាន កសិករជនបទ ហើយអាចរកបានជាទម្រង់អេឡិចត្រូនិច តាម អាសយដ្ឋានវេបសាយ www.telecentercambodia.org។ ខ្លឹមសារ ស្តីពីសត្វល្អិត និងជម្ងឺ និង ការគ្រប់គ្រងការពារ សម្រាប់ដំណាំ ត្រសក់ផ្អែមនេះ មិនមានបញ្ចូលក្នុងខិត្តបណ្ណ័ នេះឡើយ។

| រូបភាព | ពិពណ៌នា | អាយុត្រសក់ |
|---|---|---|
| ១ | ▪ រៀបចំរង (លើកពូនរង ដាក់ជីទ្រាប់បាត រៀបប្រព័ន្ធស្រោចស្រពតំណក់ទឹក និង ក្រាលកៅស៊ូគ្របរង) | ថ្ងៃទី ១ |
| ២ | ▪ បណ្តុះកូន | ថ្ងៃទី ២ |
| ៣ | ▪ ថែទាំកូន ក្នុងរោងកូនធ្វើសំណាញ់មុងពណ៌ស (ដាំនៅពេលកូនមានអាយុ ១២ថ្ងៃ) | ថ្ងៃទី ១២ទៅទី ១៤ |
| ៤ | ▪ ការដាំកូន<br>(ចោះកៅស៊ូគម្របរងដោយកំប៉ុងក្តៅ ភ្លាមមុនពេលដាំ (ហាមចោះទុកយូរ ក្រដាំ) | ថ្ងៃទី ១៤ |
| ៥ | ▪ រៀបចំទ្រើង ខ្សែចងដើម និង ការថែទាំ<br>▪ កាត់តែងមែកផ្កា កាត់ខ្នែង និងផ្កាក្តិបដែលមិនត្រូវការ និងការរុំដើមឱ្យតោងខ្សែទ្រើង ។ (ចាប់ពី១២ថ្ងៃ បន្ទាប់ពីដាំ ហើយបន្តកាត់ត្រួយខ្នែង/ផ្កា រហូតដល់ពេលប្រមូលផល)<br>▪ ប្រើប្រាស់ជីកំប៉ុស្តិ៍ទឹកជំនួយដើមស្លឹក ចាប់ពីក្រោយដាំបាន ៧ ថ្ងៃ (៥ ថ្ងៃម្តង) ដើម្បីឱ្យ ដើមលូតលាស់បានល្អ រហូតដល់ទុកបានក្តិប ទើបប្តូរទៅប្រើប្រាស់ ជីទឹកជំនួយផ្លែវិញ | ថ្ងៃទី ១៤<br>ដល់ ថ្ងៃទី ៧៥ |
| ៦ | ▪ រើសបំរុងក្តិបកាន់ផ្លែ (ចំនួន ៣ នៅថ្នាំងពីទី ៨ ដល់ ១៣)<br>▪ កាត់ត្រួយខ្នែងដែលទុកក្តិប និងតាមដានសត្វល្អិតចង្រៃ ជម្ងឺ និង ការវិវឌ្ឍន៍របស់ដំណាំ | ថ្ងៃទី ៤៥<br>(៣០ថ្ងៃបន្ទាប់ពីដាំ) |
| ៧ | ▪ ជ្រើសរើសយកក្តិប ១ ទុកឱ្យធំយកផ្លែ (ចន្លោះពី ៣០ ទៅ ៤៥ ថ្ងៃ បន្ទាប់ពីដាំកូន)<br>▪ ចងយួរបន្តោងផ្លែ ឱ្យផុតពីដី (※ មិនត្រូវទាញខ្នែងមានក្តិបខ្លាំងពេក ប្រយ័ត្នកាច់គ្រេចខ្នែងផ្លែ) | ថ្ងៃទី ៤៥<br>ដល់ថ្ងៃទី ៦០ |
| ៨ | ▪ ក្រៀវត្រួយដើមមេ បន្ទាប់ពីចេញផុតស្លឹកទី ២៣ ដល់ ២៥ ។ | ថ្ងៃទី ៦០ |
| ៩ | ▪ ថែទាំដើម ផ្លែ និង ស្រោចទឹក។<br>▪ ស្រោចទឹក រៀងរាល់ ២ថ្ងៃម្តង និងជីកំប៉ុស្តិ៍ទឹកជំនួយផ្លែផ្អែម រៀងរាល់ ៥-៧ ថ្ងៃម្តង។ | ថ្ងៃទី៤៥<br>ដល់ថ្ងៃទី៧៥ |
| ១០ | ▪ ដំណាក់កាលទុំ ។ ជាទូទៅវាអាចចាប់ផ្តើមទុំចាប់ពីអាយុកាល ៦០ ថ្ងៃ បន្ទាប់ពីដាំកូន អាស្រ័យលើលក្ខខណ្ឌអាកាសធាតុ (រដូវប្រាំង ក្តៅ ឆាប់ទុំ)។ | ថ្ងៃទី ៧០<br>ដល់ថ្ងៃទី៨០ |
| ១១ | ▪ ប្រមូលផល ។ ការថែទាំ ដើមឱ្យនៅរស់រហូតដល់ដំណាក់កាលប្រមូលផល។<br>▪ ប្រមូលផលបណ្តើៗ តែផ្លែទុំល្អ និង រើសផ្លែធំស្មើ វេចខ្ចប់ដាក់កេះ/ឡាំង សម្រាប់លក់ | ថ្ងៃទី ៧០ - ៨០<br>(អាស្រ័យតាមពូជ) |

## ខ. តម្រូវការទូទៅ និង រដូវកាលដាំដុះ

ត្រសក់ផ្អែម ត្រូវការពន្លឺថ្ងៃ ហើយងាយនឹងរងការបំផ្លាញពីជម្ងឺ និង សត្វល្អិត។ ត្រសក់នេះងាយរងជម្ងឺផ្សិត និងសត្វល្អិតបំផ្លាញជាង ដំណាំក្នុងអំបូរវា (ដូចជា ត្រសក់ ឪឡឹក ត្រឡាច) ដូច្នេះ មិនត្រូវ ដាំវាជាប់ក្បែរ ក្រោមខ្យល់ដំណាំទាំងនេះ ឬ ដំណាំស្ពៃខាត់ណា ឡើយ។ ជាទូទៅត្រសក់ផ្អែម តែងជួបប្រទះ ជម្ងឺ និងការបំផ្លាញពី សត្វល្អិត ប៉ុន្តែការបំផ្លាញ អាចជះផលប៉ះពាល់អាក្រក់ខ្លាំងដល់ ផលត្រសក់ សារតែដំណាំនេះ ទុកតែមួយផ្លែ។ បើជម្ងឺ ឬ សត្វល្អិត ធ្វើឱ្យខូចខាតដល់មួយដើម គឺ បាត់ផល ១ដើម តែម្តង។ ដូច្នេះ វិធានការបង្ការការពារ (ការរើសទីតាំងចំការ ការថែទាំកូន និង ការ សំអាត អនាម័យចំការ) អាចរួមចំណែកកាត់បន្ថយការខូចខាត។ ការថែទាំ និងពិនិត្យតាមដានដំណាំ ជាប្រចាំ គឺជាការចាំបាច់។

រដូវដាំដុះដែលល្អបំផុត សម្រាប់ដំណាំនេះ នៅកម្ពុជា គឺ រដូវប្រាំង បន្ទាប់ពីភ្លៀងចាប់ដើមអស់ និងទឹកស្រកចុះ ទៅតាមទីតាំងចំការ (ដីទួល ឬ ដីស្រែ)។ ពេលសមស្របខ្លាំង សម្រាប់ចាប់ផ្តើមដាំ គឺ ពីខែធ្នូ ដល់ ខែកុម្ភៈ។ ដីស្រែមានល្បាយខ្សាច់ ផ្តល់ផ្លែតូច តែ ស្រួយ និង ផ្អែមជាង ដីល្បាប់កណ្តុង។ ដើម្បីដាំដំណាំនេះ ឱ្យបានផល និង គុណភាពល្អ កសិករត្រូវការជីកំប៉ុស្តិ៍ ៣ ប្រភេទ គឺ **កំប៉ុស្តិ៍គោក កំប៉ុស្តិ៍ទឹកបំប៉នស្លឹកដើម និង កំប៉ុស្តិ៍ទឹកជំនួយផ្លែឱ្យផ្អែម**។ របៀបធ្វើ និង ប្រើជីទាំងនេះ មាននៅក្នុងខិត្តប័ណ្ណធ្វើជីកំប៉ុស្តិ៍ និង សៀវភៅណែនាំបច្ចេកទេស ស្តីពីដំណាំនេះ។

## គ.វិធីដាំ និង ថែទាំ

### *គ.១. ការបណ្តុះកូនត្រសក់*



ថ្នាលបណ្តុះកូន ត្រូវដាក់នៅកន្លែង ដែលមានកំដៅថ្ងៃល្អ។ គេ អាចប្រើដីបណ្តុះកូនលាយស្រាប់ ដែលអាច ទិញបានពីផ្សារ ឬ រៀបចំដីបណ្តុះកូន ដែល ផ្សំ (ក្នុងបរិមាណស្មើគ្នា) ពី៖ ស្រកីដូងម៉ដ្ឋ ដី ស្រទាប់លើ ជីកំប៉ុស្តិ៍គោក និង ផេះធ្យូងអង្កាម ហើយចំហិន សំលាប់មេរោគបានល្អ។ ខាងក្រោម ជាវិធីបណ្តុះកូនត្រសក់៖



- ដាស់ដំណេកគ្រាប់សិន ដោយដាក់គ្រាប់ត្រាំក្នុងទឹកក្តៅអ៊ុនៗ
- យកដីខ្សាច់ លាងឱ្យស្អាត រួច ដាក់ហាលថ្ងៃ ឬ លីងដីខ្សាច់ឱ្យ បានស្ងួតល្អ រួចទុកមួយឡែក។
- ចាក់ទឹកក្តៅ១កូនកែវ សម្រាប់ដី ខ្សាច់ ១គីឡូ(ផ្សើមដីតិចៗ)។
- ដាក់ក្រណាត់ដែលមានពង្រាយគ្រាប់ត្រសក់ នៅលើដីខ្សាច់ នោះ រួចខ្ចប់រុំក្រណាត់ឱ្យជិតល្អ ហើយដាក់ដីខ្សាច់គ្របពីលើ ផ្លាប់ក្នុងធុងទឹកកក ដែលដាក់ហាលថ្ងៃរយៈពេល ២៤ ម៉ោង ទើបយកគ្រាប់ចេញពន្លក ទៅដាក់លើថាសបណ្តុះកូន។

- ដាក់ថាសបណ្ដុះ ក្នុងរោងបណ្ដុះកូន ហើយដាក់ឱ្យត្រូវពន្លឺថ្ងៃ ស្រោចទឹកពេលព្រឹក មួយដង ក្នុងមួយថ្ងៃ ។




រោងបណ្ដុះកូន ធ្វើពីសំណាញ់ល្អិត (ពណ៌ស ដោយសារ វា មិនស្រូវទាក់ទាញសត្វល្អិត)។ ផ្ទៃដី ៣ អារ ត្រូវការកូនពី ៧០០ ទៅ ៨០០ដើម បណ្ដុះក្នុងរោងទំហំ ១,៥ម៉ែត្រ x ២ម៉ែត្រ កំពស់ ១,៥ ម៉ែត្រ។ រោងបណ្ដុះកូន ត្រូវធ្វើផុតពីដី ហើយឱ្យអាចចល័តផ្លាស់ប្ដូរទីតាំងបាន ដើម្បីផ្ដល់លក្ខខណ្ឌសមស្របសម្រាប់ការលូតលាស់ (ពង្រឹងកូន ដោយវាឱ្យត្រូវពន្លឺថ្ងៃខ្លាំង និង បន្ថយស្រោចទឹក ២ថ្ងៃ មុនដាំ) និង បង្ការពីការឃាយីពីសត្វល្អិត ដល់កូនត្រសក់។ កូនត្រសក់ អាចយកទៅដាំបាន ពេលវាមានអាយុពី១០ ទៅ ១២ថ្ងៃ។

## គ.២. ការរៀបចំរងសម្រាប់ដាំកូន

ការរៀបចំរងដាំ ចាប់ផ្ដើមពីការរៀបចំដី (ភ្ជួរហាលដី ១៥ថ្ងៃ មុនដាំកូន) និង រាស់បំបែកឱ្យបានល្អ មុននឹងលើករង។ ការលើករង ត្រូវដាក់ជីកប់រងទ្រាប់បាត និង រៀបចំដាក់ប្រព័ន្ធស្រោចស្រពដោយដំណក់ទឹក (ខ្រឹព) និង ស្រោចទឹកឱ្យជោគល្អ រួចគ្រប់រងនឹងកៅស៊ូគម្របរង យ៉ាងតិច ៧ថ្ងៃ មុនដាំ។

| វត្ថុធាតុ | កម្រិតប្រើ (គីឡូ) | ផ្ទៃដីរង (ម៉ែត្រការ៉េ) |
|---|---|---|
| ជីបារ៉ា (ប្រភេទ 20-20-15) | ១,៥ | ១០០ |
| ជីកំប៉ុស្តិ៍គោក | ពី ២០០ ទៅ ៣០០ | ១០០ |
| កំបោរស | ពី ៣ ទៅ ៤ | ១០០ |

លើករងកំពស់ពី ២ ទៅ ៤តឹក អាស្រ័យតាមរដូវ (ប្រាំង / វស្សា) និង ទីតាំងចំការ (រដូវវស្សា)។ បន្ទាប់ពីលើករងរួច ត្រូវស្រោចទឹកឱ្យជោគល្អ រួចគ្រប់រងនឹងកៅស៊ូគម្របរង យ៉ាងតិច ៧ថ្ងៃ មុនដាំ។ មុននឹងដាំ ត្រូវចោះថង់ប្លាស្ទិចគ្របរង តាមចន្លោះគុម្ពគំរូ។




ត្រូវដាំកូនត្រសក់ នៅពេលរសៀល ត្រជាក់ ។ ដើម្បីដាំកូន ឱ្យបានត្រឹមត្រូវ និង រហ័ស យើងត្រូវ ៖

- ដាក់រាយជីកំប៉ុស្តិ៍សម្រាប់ទ្រាប់បាតរណ្ដៅកូន នៅលើរងក្បែរៗរណ្ដៅ ដែលទើបចោះកៅស៊ូគ្របរងរួច។
- កាយដីក្នុងរណ្ដៅចេញបន្តិច រួចកាយដីកំប៉ុស្តិ៍ចូលបន្តិច ច្របល់ឱ្យសព្វ ហើយកាយដី វែកជារណ្ដៅ។
- ដកកូនចេញពីកន្ទោង/ថាសបណ្ដុះដោយថ្នមៗ រួចហើយដាក់កូនត្រសក់ចូលក្នុងរណ្ដៅរួចកាយដីកំប៉ុស្តិ៍ លុបរណ្ដៅកប់ត្រឹមគល់ (ដីបណ្ដុះ) កូនត្រសក់ ។
- ស្រោចទឹកល្មម ដើម្បីឱ្យដីចូលកប់ជិតជុំវិញឫស បានល្អ ។




## គ.៣. វិធីចងចំណាររទ្រើងត្រសក់

ប្រើខ្សែវេញចងក្រវាត់ ស្រាក់លើបង្គោលទ្រើង ជា ៣ជាន់ (ខ្សែខាងក្រោម ជាប់នឹងចងគម្របដី ខ្សែកណ្ដាល កំពស់ប្រហែល ១ ម៉ែត្រ និង ខ្សែទី ៣ កំពស់ប្រហែល ១,៥ ម៉ែត្រ ពីដី)។ ប្រើខ្សែនីឡុងអំបោះវេញតូច ចងប្រទាក់នឹងខ្សែបង្គោលទ្រើង ៣ជាន់ តាមដើមនីមួយៗ សម្រាប់ឱ្យដើមត្រសក់ តោងវារឡើង។




## គ.៤. ការតាក់តែងមែក

ត្រសក់ចាប់ចេញផ្កា តាំងពីគល់ធាងស្លឹកដំបូង ប៉ុន្តែគេត្រូវកាត់វាចេញ ដើម្បីឱ្យដើម និង ក្តិបទុកយកផ្លែ ថ្លោសល្អ និង លូតលាស់ឆាប់រហ័ស ។ ឧបករណ៍ដែលអាចប្រើកាត់ គឺ កន្ត្រៃ ដោយមានទឹកសាប៊ូ/អាល់កុល សម្រាប់សម្លាប់មេរោគ ។ ត្រូវចាំថា បន្ទាប់ពីកាត់ខ្នែងដើមនិមួយៗហើយ ត្រូវជ្រលក់កន្ត្រៃនឹងទឹកសាប៊ូ ឬ អាល់កុល ម្ដង។ ខ្នែង និងស្លឹក ដែលកាត់ ត្រូវប្រមូលដាក់ថង់ប្លាស្ទិច ឬ ធុង យកទៅដុត ឬ កប់ចោល ឱ្យឆ្ងាយពីចំការ កុំឱ្យឆ្លងជម្ងឺ។ ស្លឹកខាងក្រោមៗ ពិសេស ស្លឹកជាប់នឹងប្លាស្ទិចគ្របដី ត្រូវកាត់ចោលឱ្យស្រឡះគល់ ដើម្បីកុំឱ្យចំលងជម្ងឺ ពីដី មកដើម និង ទៅស្លឹកខាងលើៗ ហើយអាចឆ្លងរាលដាល ពេញដើមទាំងមូល។



ខ្នែងដែលត្រូវទុកយកក្តិប(ផ្លែ) គឺ ចាប់ពីខ្នែង ទី ៨ ដល់ ទី១២ ។ ហើយបន្ទាប់ពីក្តិបផ្លែ កាន់ហើយ គេត្រូវកាត់ (ក្រៀវ) ត្រួយខ្នែងទុកក្តិប ត្រឹមថ្នាំងទី២ (បន្ទាប់ពីថ្នាំងមានក្តិប) ចោល ដើម្បីឱ្យដើមចិញ្ចឹមក្តិប ដែលទុកយកផ្លែនោះ ឱ្យបានល្អ។




## *គ.៥. ការចងផ្លែ*

បន្ទាប់ពីសំរេចទុកផ្លែចុងក្រោយមួយហើយ ត្រូវកាត់ក្តិបផ្សេងទៀតចោល។ ចំពោះផ្លែដែលត្រូវទុកនោះ ត្រូវចងបន្តោងវានឹងខ្សែទ្រើង ដើម្បីជួយទប់ដើម និងការពារ កុំឱ្យវា ប៉ះនឹងដី ឬ កៅស៊ូគម្របដី ដែលអាចធ្វើឱ្យផ្លែរលួយ មានស្នាម ឬ ក្រិនគូថ ឬសត្វល្អិតចោះ។




ការចងបន្តោងផ្លែ គឺ ប្រើខ្សែប៉ៃ ចងសម្លាប់មុខ (កុំឱ្យរអិលរូតរឹត) កណ្តាង់ទងផ្លែ ដោយទុកចន្លោះឱ្យរលុង រវាងខ្សែ និង ទងផ្លែ។ គួរប្រើខ្សែប៉ៃ មានពណ៌មិនស្រស់ឆើត ដូចជា ពណ៌ខ្មៅ ទឹកប្រាក់/ប្រផេះ ឬ ពណ៌ស ដែលជាពណ៌មិនសូវទាក់ទាញសត្វល្អិត។

បន្ទាប់ពីទុកក្តិបយកផ្លែហើយ ត្រូវបន្តកាត់ខ្នែង ផ្កា និងក្តិប ដែលមិនត្រូវការ ចោល។ ពេលត្រសក់ចេញផុតស្លឹកទី ២៤ ហើយ ត្រូវក្រៀវត្រួយដើមមេ ចោល។ ការកាត់ត្រួយ ខ្នែង និង ផ្កា ដែលមិនត្រូវការចាល ក្រៅពីជួយសន្សំជី និងសារធាតុចិញ្ចឹមសម្រាប់ផ្លែ វាក៏អាចជួយកាត់បន្ថយសត្វល្អិតបំផ្លាញដើមត្រសក់។

## *គ.៦. ការស្រោចទឹក*

ត្រសក់ផ្អែម ជាដំណាំ ត្រូវការទឹកល្មម ព្រោះទឹកសើមជ្រុល ងាយបង្កឱ្យមានជម្ងឺផ្សិតលើស្លឹកដើម និង ផ្លែ ។ វិធីស្រោចល្អ គឺ ត្រូវប្រើប្រព័ន្ធស្រោចស្រពដំណក់ទឹក ដែលអាចជួយគ្រប់គ្រងបរិមាណទឹក និង ការបំប៉នជីទឹក ដែលដំណាំនេះ ត្រូវការសម្រាប់ការលូតលាស់ និង ជំនួយផ្លែឱ្យផ្អែម ។ *មិនត្រូវស្រោចត្រសក់ ដោយបាញ់ស្រោចទឹក ពីលើស្លឹកដើម ឡើយ ព្រោះវាងាយបង្កជម្ងឺផ្សិតលើស្លឹកនិងដើម។* ការស្រោចទឹកទទេ(គ្មានជី) គួរធ្វើនៅពេលព្រឹក ហើយ ស្រោចលាយជីបំប៉នកំប៉ុស្តិ៍ទឹក នៅពេលល្ងាច។ ការស្រោចទឹក អាចធ្វើមួយថ្ងៃ ឬ ពីរថ្ងៃម្តង អាស្រ័យតាមប្រភេទដី។

## *គ.៧. ការបំប៉នជីទឹកជំនួយដើមស្លឹក*

ការបំប៉នជីកំប៉ុស្តិ៍ទឹក អាចធ្វើឡើងតាមរយៈប្រព័ន្ធស្រោចស្រពដំណក់ទឹក (ឧ្រីព) ដោយបញ្ចូលទឹកជី ទៅក្នុងបំពង់បូម លាយជាមួយទឹកស្រោច ។ ប្រើជីកំប៉ុស្តិ៍ទឹក ១លីត្រ លាយជាមួយទឹក ២០លីត្រ ប្រើមួយសប្តាហ៍ម្តង។ វិធីប្រើជីទឹក គឺស្រោចលាយតាមប្រព័ន្ធស្រោចស្រពដំណក់ រាល់៥ថ្ងៃម្តង (គឺថា ស្រោច<u>ទឹកទទេចំនួន ៤ថ្ងៃ ជាប់គ្នា</u> ហើយ នៅថ្ងៃទី៥ <u>ទឹកមានលាយទឹកជី</u>) ។




រយៈពេលនៃការស្រោចម្តងៗ គឺ ប្រមាណ ២០នាទី (សម្រាប់ផ្ទៃដី ៣០០ ម៉ែត្រការ៉េ) គឺ ចាប់ផ្តើមដោយស្រោចទឹកទទេ រយៈពេល ៥នាទី បន្ទាប់មក បើកបញ្ចូលជីកំប៉ុស្តិ៍ទឹក តិចៗក្នុងប្រព័ន្ធទុយោស្រោចស្រពឌ្រីប រយៈពេល ១០នាទី ហើយចុងក្រោយរយៈពេល ៥នាទី ដោយទឹកទទេ។ ការស្រោចបែបនេះ ជួយឱ្យទឹកជី ជ្រាបសព្វបានល្អ និង ងាយស្រួលបឺតស្រូបយកដោយ ឫសរុក្ខជាតិ ហើយអាចជួយលាងសំអាតប្រព័ន្ធទុយោស្រោចដំណក់ទឹក ដែរ។ ការស្រោចជីកំប៉ុស្តិ៍ទឹកជំនួយដើមស្លឹក ធ្វើឡើង បន្ទាប់ពីដាំកូនបាន ៧ថ្ងៃ រហូតដល់បានត្រសក់មានអាយុ ៤៥ ថ្ងៃ (ក្រោយដាំកូន) ឬ រហូតដល់ការទុកក្តិបល្អ មួយ (សម្រាប់យកផ្លែធំ)។

## **ឃ. ការប្រមូលផល**

ជាទូទៅ ផ្លែត្រសក់អាចទុំពីអាយុ ៦៥ថ្ងៃ ឬ ៧៥ថ្ងៃ បន្ទាប់ពីដាំកូន (តាមពូជ K2122 ឬ T778)។ ដើម្បី ឱ្យផ្លែមានរសជាតិផ្អែមល្អ គួរផ្តាច់ទឹក(ឈប់ស្រោច) មុនពេលបេះ យ៉ាងតិច ២ថ្ងៃ ។ ប៉ុន្តែ បើផ្តាច់ទឹក មុនយូរពេក អាចធ្វើឱ្យដើមស្វិត ហើយប៉ះពាល់ដល់ផ្លែ ។ គេអាចសំគាល់ផ្លែត្រសក់ទុំ សម្រាប់ពូជសំបករលោង (K2122) ដោយសំបកខាងក្រៅវា ឡើងរលោង ពណ៌ស លាយលឿងព្រឿងៗ។




ចំពោះពូជក្រទ្បាសំណាញ់ (T778) គេអាចសំគាល់ផ្លែទុំ ល្មមបេះ នៅពេលក្រទ្បាសំណាញ់សំបករបស់វា លេចចេញច្បាស់ ដល់គល់ទង សំបកក្រៅវាឡើងពណ៌បៃតងប្រផេះ ឆ្នូតសំណាញ់ មានស្នាមប្រេះ ប្រទាក់ក្រទ្បាគ្នា ។ ចំពោះពូជនេះ គេក៏អាចបេះហូបបានភ្លាមៗ (តែពេលហូបទៅ មានអារម្មណ៍ រមាស់មាត់តិចៗ) ។ ដូច្នេះជាការល្អ គេគួរបេះទុកក្នុងម្លប់ រយៈពេល ១ ឬ ២ថ្ងៃ ដើម្បីឱ្យវាភ្លេចព្រៃ)។ គេត្រូវបេះត្រសក់នៅពេលព្រឹក (មុនម៉ោង ៩ព្រឹក) ដើម្បីឱ្យផ្លែវាផ្អែម ព្រោះបើបេះថ្ងៃជាងនេះ ជាតិស្ករក្នុងផ្លែ ថយចុះ។



**ព័ត៌មានបន្ថែម សូមទាក់ទងតាម:** livleanghy@gmail.com